# ពិធីបុណ្យមាឃបូជា

## វគ្គទី ១

ព្រះច័ន្ទមានពន្លឺភ្លឺស្រទន់កំពុងគោចរទៅក្នុងអាកាស ក្នុងថ្ងៃ ១៥ កើតពេញបូណ៌មី ខែ មាឃ ដែលជាថ្ងៃសំខាន់ក្នុងព្រះពុទ្ធសាសនា ។

១៥ កើតពេញបូណ៌មី ខែ មាឃ ជាថ្ងៃសំខាន់មួយក្នុងព្រះពុទ្ធសាសនា ដែលពុទ្ធសាសនិកជន ទាំងបព្វជិត ទាំងគ្រហស្ថ នាំគ្នាប្រារព្ធធ្វើពិធីបុណ្យមាឃបូជា ។

មាឃបូជាប្រារព្ធធ្វើឡើងដោយហេតុ ៣ យ៉ាង

១-ជាថ្ងៃប្រជុំប្រកបដោយចតុរង្គសន្និបាត

២-ជាថ្ងៃព្រះពុទ្ធអង្គ ទ្រង់សម្តែងឱវាទបាតិមោក្ខ ដែលជាបេះដូងធម៌

៣-ជាថ្ងៃដែលព្រះពុទ្ធអង្គ ដាក់ព្រះជន្មាយុសង្ខារដើម្បីបរិនិព្វាន

## វគ្គទី ២

ក្នុងថ្ងៃ ១៥ កើតពេញបូណ៌មី ខែ មាឃ ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ ព្រះអង្គទ្រង់គង់ក្នុងល្អាងសូករខតា នាភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ ពេលនោះ ព្រះពុទ្ធអង្គទ្រង់សម្តែងនូវទីឃនខសូត្រ ប្រោសបរិព្វាជកឈ្មោះ ទីឃនខៈ ។ ខណៈពេលនោះដែរ ព្រះធម្មសេនាបតីសារីបុត្រ និមន្តស្ថិតនៅខាងស្តាំ បក់ផ្លិតថ្វាយព្រះសម្មាសម្ពុទ្ធបានពិចារណានូវព្រះធម៌ តាមក្រសែ ដែលព្រះពុទ្ធអង្គទ្រង់សម្តែង ក៏បានសម្រេចជាព្រះអរហន្តដល់ទីបំផុតនៃសាវកបារមីញាណ និងបញ្ញា ១៦ ។ ចំណែកទីឃនខៈ ក៏បានសម្រេចនូវសោតាបត្តិផល ។

កាលព្រះអាទិត្យទៀបអស្តង្គត ព្រះអង្គទ្រង់បញ្ចប់ព្រះធម្មទេសនានេះ ហើយទ្រង់និមន្តចុះពីភ្នំគិជ្ឈកូដ ព្រះអង្គទ្រង់យាងទៅកាន់វត្តវេឡុវ័ន ហើយប្រជុំសាវកប្រកបដោយអង្គ ៤ ។

### ព្រឹត្តិការណ៍ទី ១ ចតុរង្គសន្និបាតប្រកបដោយអង្គ ៤គឺ

១-ថ្ងៃឧបោសថ ១៥ កើតពេញបូណ៌មី ខែ មាឃ

២-ព្រះភិក្ខុ ១,២៥០អង្គ ប្រជុំគ្នាតាមធម្មតារបស់ខ្លួនមិនមានអ្នកនិមន្ត

៣-ព្រះភិក្ខុទាំងនោះ សុទ្ធតែជាព្រះអរហន្ត អភិញ្ញា ៦

៤-ព្រះភិក្ខុទាំងនោះ សុទ្ធតែជាឯហិភិក្ខុ ។

**ព្រឹត្តិការណ៍ទី ២ សម្តែងបាតិមោក្ខដែលជាបេះដូងធម៌**

កាលព្រះអរហន្ត ១,២៥០ អង្គ បានជួបជុំគ្នាហើយ ។ ព្រះពុទ្ធអង្គទ្រង់សម្តែងនូវឱវាទបាតិមោក្ខថា ៖

**ខន្តី បរមំ តបោ តិតិក្ខា**

និព្វានំ បរមំ វទន្តិ ពុទ្ធា

ន ហិ បព្វជិតោ បរូបឃាតី

ន សមណោ ហោតិ បរំ វិហេឋយន្តោ ។

*អធិវាសនខន្តី ពោលគឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម*
*ព្រះពុទ្ធទាំងឡាយតែងត្រាស់ថា ព្រះនិព្វាន ជាធម្មជាតដ៏ឧត្តម*
*បុគ្គលណាសម្លាប់សត្វដទៃ បៀតបៀនសត្វដទៃ*
*បុគ្គលនោះ មិនឈ្មោះថា បព្វជិតឡើយ*
*បុគ្គលណាសម្លាប់សត្វដទៃ បៀតបៀនសត្វដទៃ*
*បុគ្គលនោះ មិនឈ្មោះថា សមណៈឡើយ ។*

សព្វបាបស្ស អករណំ  កុសលស្សូបសម្បទា

សចិត្តបរិយោទបនំ  ឯតំ ពុទ្ធានសាសនំ។

*ការមិនធ្វើបាបទាំងពួង ការបំពេញកុសល ការញុំាងចិត្តរបស់ខ្លួន*
*ឲ្យផូរផង់ ទាំង ៣ នេះ ជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។*

អនូបវាទោ អនូបឃាតោ  បាតិមោក្ខេ ច សំវរោ

មត្តញ្ញុតា ច ភត្តស្មឹ  បន្តញ្ច សយនាសនំ

អធិចិត្តេ ច អាយោគោ  ឯតំ ពុទ្ធានសាសនន្តិ។

*ការមិនពោលតិះដៀល ការមិនបៀតបៀន ការសង្រួមក្នុងបាតិមោក្ខ ការៈជាអ្នកដឹងប្រមាណក្នុងភត្ត ទីដេកទីអង្គុយដ៏ស្ងាត់ ការបំពេញព្យាយាមក្នុងអធិចិត្ត ទាំង ៦ នេះជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។*

## ព្រឹត្តិការណ៍ទី ៣ ដាក់ព្រះជន្មាយុសង្ខារ

អប្បោស្សុក្កោ ត្វំ បាបិម ហោហិ, ន ចិរំ តថាគតស្ស បរិនិព្វានំ ភវិស្សតិ ។ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សតិ ។

*ម្នាលមារមានចិត្តបាប ចូរអ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគត មិនយូរប៉ុន្មានទេ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។*

តុលមតុលញ្ច សម្ភវំ ភវសង្ខារមវស្សជ្ជិ មុនិ
អជ្ឈត្តរតោ សមាហិតោ អភិន្ទិ កវចមិវត្តសម្ភវំ ។

*ព្រះពុទ្ធជាអ្នកប្រាជ្ញ ទ្រង់ពិចារណាឃើញនូវព្រះនិព្វាន ដែលមានគុណថ្លឹងមិនបានផង នូវភពផង ទ្រង់លះបង់ នូវសង្ខារដែលនាំសត្វទៅកាន់ភពផង ទ្រង់ត្រេកអរនូវ អារម្មណ៍ខាងក្នុង ដោយអំណាចវិបស្សនា មានព្រះហឫទ័យ តាំងមាំហើយ ដោយអំណាចសមថៈផង ទ្រង់ទម្លាយនូវ បណ្តាញគឺ កិលេសដែលកើតមាននៅក្នុងខ្លួនដូចជាក្រោះ ។*

ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា, អប្បមាទេន សម្បាទេថ ។ នចិរំ តថាគតស្ស បរិនិព្វានំ ភវិស្សតិ ។ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងដាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយ មានសេចក្តីវិនាសទៅជាធម្មតា អ្នកទាំងឡាយចូរញុំាងកិច្ចទាំងពួងឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ ។ បរិនិព្វាននឹងមានដល់តថាគតមិនយូរឡើយ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។

ទហរាបិ ច យេ វុឌ្ឍា
យេ ពាលា យេ ច បណ្ឌិតា
អឌ្ឍា ចេវ ទលិទ្ទា ច
សព្វេ មច្ចុបរាយណា ។
យថាបិ កុម្ភការស្ស
កតំ មត្តិកភាជនំ
ខុទ្ទកញ្ច មហន្តញ្ច
យញ្ច បក្កំ យញ្ច អាមកំ
សព្វំ ភេទនបរិយន្តំ
ឯវំ មច្ចាន ជីវិតំ ។

ពួកជនណាៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី
អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅពីខាងមុខ
ភាជន៍ដី ដែលស្មូនឆ្នាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុតយ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។

បរិបក្កោ វយោ មយ្ហំ

បរិត្តំ មម ជីវិតំ

បហាយ វោ គមិស្សាមិ

កតំ មេ សរណមត្តនោ ។

*វ័យរបស់តថាគតចាស់ហើយ*
*ជីវិតរបស់តថាគតមានប្រមាណតិច*
*តថាគតនឹងលះបង់អ្នកទាំងឡាយហើយទៅ*
*ឯទីពឹងចំពោះខ្លួន តថាគតបានធ្វើទុកហើយ ។*

អប្បមត្តា សតីមន្តោ

សុសីលា ហោថ ភិក្ខវោ

សុសមាហិតសង្កប្បា

សចិត្តមនុរក្ខថ ។

យោ ឥមស្មឹ ធម្មវិនយេ

អប្បមត្តោ វិហស្សតិ

បហាយ ជាតិសំសារំ

ទុក្ខស្សន្តំ ករិស្សតិ ។

*ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាទ*
*ត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់នឹងល្អ*
*ចូររក្សាចិត្តរបស់ខ្លួនឲ្យរឿយៗចុះ ។ ភិក្ខុណាមិនប្រមាទ*
*ហើយនៅក្នុងធម៌វិន័យនេះ ភិក្ខុនោះ នឹងលះបង់ជាតិសង្សារៈ*
*ហើយធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខបានមិនខាន ។*